01223554

E202/208/3/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ផ្នែកសន្តិសុខកម្ពុជា

សាធារណៈ / Public

# គោរពជូន

## ឯកឧត្តម ប្រធានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**កម្មវត្ថុ**÷ របាយការណ៍ស្តីពីការពន្យាពេលការអនុវត្តដីការបង្គាប់ឲ្យនាំខ្លួនសាក្សី ដែលបដិសេធមិនចូលមកបង្ហាញខ្លួន ។

**យោង**÷ -ដីការបង្គាប់ឲ្យនាំខ្លួនសាក្សីដែលបដិសេធមិនចូលបង្ហាញខ្លួនលេខ E202/208/2 ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦ របស់អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

តបតាមកម្មវត្ថុនិងយោងខាងលើ ក្រុមមន្ត្រីនគរបាលយុត្តិធម៌ សូមអនុញ្ញាតគោរពរាយការណ៍ជូន **ឯកឧត្តម ប្រធានអង្គជំនុំជម្រះសាលាដំបូង** នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេត្តាជ្រាបថា៖ ក្រោយពីទទួលបានដីការបង្គាប់ឲ្យនាំខ្លួនសាក្សីដែលបដិសេធមិនចូលមកបង្ហាញខ្លួនលេខ E202/208/2 ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅវេលាម៉ោង ២៖៣០នាទី ល្ងាច ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦ ផ្នែកសន្តិសុខកម្ពុជានិងមន្ត្រីនគរបាលយុត្តិធម៌បានត្រៀមខ្លួនរួចរាល់អនុវត្តដីការបង្គាប់ឲ្យនាំចូលខ្លួនសាក្សី ដែលបដិសេធមិនចូលមកបង្ហាញខ្លួនដោយបានសហការជាមួយមន្ត្រីមូលដ្ឋាន និង អង្គភាពគាំពារសាក្សី និង អ្នកជំនាញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយបានកំនត់ពេលវេលា និងទីតាំងដើម្បីចុះអនុវត្តនៅព្រឹកម៉ោង ៧ ៖ ០០នាទីព្រឹក។ ក្រោយមកយើងខ្ញុំបានទទួលនូវការស្នើសុំយ៉ាងទទូចពីគណៈដឹកនាំសាសនា ដោយពួកគាត់ស្នើសុំពេលវេលាដើម្បីបញ្ចុះបញ្ចូលឲ្យសាក្សីទៅចូលបង្ហាញខ្លួនដោយស្ម័គ្រចិត្ត ដោយហេតុផលថាការអនុវត្តបែបចាប់បង្ខំនេះនឹងធ្វើឲ្យប្រជាពលរដ្ឋខ្មែរឥស្លាមមានការយល់ច្រឡំ និងអាចឈានដល់មានការតវ៉ាផ្សេងៗ និងអាចមានអំពើហឹង្សា ។ ក្រោយពីបានពិនិត្យស្ថានការឃើញថាសាក្សីត្រូវនាំខ្លួនជាជនជាតិខ្មែរឥស្លាម ហើយមានឋានៈខ្ពស់នៅក្នុងគណៈដឹកនាំសាសនា និងដោយមានការស្នើសុំផ្តល់ជំនួយពីគណៈដឹកនាំសាសនាក្នុងការជួយពន្យល់សាក្សីអោយចូលបង្ហាញខ្លួនដោយស្ម័គ្រចិត្តផងនោះ ដើម្បីបញ្ចៀសរាល់បញ្ហាដែលអាចកើតមានឡើងដោយយថាហេតុនោះ ទើបមន្ត្រីនគរបាលយុត្តិធម៌បានធ្វើការជូនដំណឹងដល់អង្គភាពគាំពារសាក្សី និង អ្នកជំនាញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវពត៌មានទាំងអស់ និងការសំរេចចិត្តពន្យាពេលក្នុងការអនុវត្តដីការបង្គាប់ ដើម្បីទុកពេលវេលាជូនគណៈដឹកនាំសាសនា បើមិនមានពត៌មានជាក់លាក់ដល់មន្ត្រីនគរបាលយុត្តិធម៌ទេនោះ យើងខ្ញុំនឹងអនុវត្តដីការជាកំហិត ។

នៅវេលាម៉ោង ២៖០០ ល្ងាច ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦ សាក្សីបានយល់ព្រមចូលបង្ហាញខ្លួននៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ដោយសំណូមពរសុំអោយមានជំនួយការមកចូលរួមក្នុងសវនាការជាមួយ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម ប្រធាន មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ ។

សូមឯកឧត្តម ប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦

**អនុប្រធានផ្នែកសន្តិសុខកម្ពុជា**

(signature)

**ឧត្តមសេនីយ៍ទោ ឡោ សុឡេង**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 04 / 2016
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada